សាលាដំបូងរាជធានីភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការរដ្ឋប្បវេណី

សំណុំរឿងលេខ ....

ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៩

សាលក្រមលេខ ....

ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០១៩

សាលក្រម[1]

ក្នុងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងរាជធានីភ្នំពេញ [2]

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅ

ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៩ [3] [4]

ចៅក្រមជំនុំជម្រះ

លោក J ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជី

លោកស្រី C ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

---

[1] ការសម្រេចសេចក្តី គឺចែកចេញជា សាលក្រម និង ដីកាសម្រេច (មាត្រា ១៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដូច្នេះ មានភាពចាំបាច់នៅក្នុងការបញ្ជាក់ឲ្យបានច្បាស់លាស់ថា អំពីប្រភេទនៃការសម្រេចសេចក្តីដាក់នៅត្រង់ចំណុចចាប់ផ្តើម។ ដោយសារតែ សាលក្រម និង ដីកាសម្រេចមានភាពខុសគ្នាចំពោះវិធីក្នុងការធ្វើឧបាស្រ័យជាអាទិ៍ ។ ជាគោលការណ៍បណ្តឹងឧបាស្រ័យចំពោះសាលក្រម គឺ បណ្តឹងឧទ្ធរណ៍ ហើយ បណ្តឹងឧបាស្រ័យចំពោះដីកាសម្រេច គឺ បណ្តឹងជំទាស់ (កថាខណ្ឌទី ១ មាត្រា ២៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[2] សាលក្រមរដ្ឋប្បវេណីត្រូវតែសរសេរអំពីចំណុចដែលចែងនៅក្នុងមាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[3] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៨៩ កថាខណ្ឌទី ១ ចំណុច ខ ។ សាលក្រមនឹងត្រូវកំណត់ជាស្ថាពរនូវទំនាក់ទំនងសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តិនាពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៩៤ កថាខណ្ឌទី ២) ហេតុនេះ ចាំបាច់ត្រូវសរសេរឲ្យបានច្បាស់លាស់អំពី ពេលដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។ សាលក្រមគឺជាការសម្រេចសេចក្តីរបស់តុលាការដែលត្រូវបានធ្វើឡើងដោយកំណត់ជាមុននូវទំនាក់ទំនងអង្គហេតុគិតមកដល់ត្រឹមថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។

[4] ការប្រកាសសាលក្រមត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ១៨៧ នៃក្រមរដ្ឋប្បវេណី)។ ហើយការប្រកាសសាលក្រមចាំបាច់ត្រូវធ្វើឡើងដោយផ្អែកលើច្បាប់ដើមនៃមូលសាលក្រម (កថាខណ្ឌទី ១ មាត្រា ១៨៨ នៃក្រមរដ្ឋប្បវេណី) ដូច្នេះហើយ ចាំបាច់ត្រូវតែបញ្ចប់នូវការតាក់តែងច្បាប់ដើមនៃមូលសាលក្រមឲ្យបាន គិតត្រឹមពេលប្រកាសសាលក្រម។

ដើមចោទ

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

អ្នកតំណាងដោយអាណត្តិ

លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ ....

ការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ ....

លេខទូរស័ព្ទ ៖ ....

ចុងចម្លើយ

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

អ្នកតំណាងដោយអាណត្តិ

លោក/លោកស្រី ៖ B

អាសយដ្ឋានការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ ....

ការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ ....

លេខទូរស័ព្ទ ៖ ....

អង្គហេតុ និងចំណុចវិវាទ

ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

(១) បង្គាប់ឲ្យចុងចម្លើយប្រគល់អចលនវត្ថុដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធ[5]ឲ្យទៅដើមចោទ។

(២) បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីអចលវត្ថុដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធឲ្យទៅដើមចោទ។

(៣) ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

ខ. ដំណើររឿងក្ដី និង ចំណុចវិវាទ

ខ.១. ការសង្ខេបអំពីរឿងក្ដី

នៅក្នុងរឿងក្ដីនេះ ដើមចោទបានទាមទារនូវការប្រគល់អចលនវត្ថុដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធ (តទៅហៅថា "ដី L") និង ការធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលលើអចលនវត្ថុដដែលដោយផ្អែកលើកិច្ចសន្យាលក់ទិញចុះថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៨ ពីចុងចម្លើយ។

ខ.២. អង្គហេតុដែលគ្មានវិវាទ[6]

ខ.២.១. នៅថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៨ ដើមចោទបានទិញ "ដី L" ក្នុងតម្លៃ ២០០.០០០ (ពីរសែន) ដុល្លារអាមេរិកពីចុងចម្លើយ (តទៅហៅថា "កិច្ចសន្យាលក់ទិញនៃរឿងក្ដីនេះ")។

[5] ឧបសម្ព័ន្ធ ជាឯកសារមួយដែលបានបង្កើតដើម្បីដាក់បញ្ចូលព័ត៌មាននោះ ហើយជាផ្នែកតែមួយនៃឯកសារដើម។ ដូច្នេះហើយចំពោះអនុសារនៃសាលក្រម (កថាខណ្ឌទី ២ មាត្រា ១៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ក៏ ប្រាកដជាត្រូវតែ**ធ្វើឡើងដោយរួមបញ្ចូលទាំងឧបសម្ព័ន្ធ**ផងដែរ។ ឧបសម្ព័ន្ធ គឺជាគ្រាន់តែសរសេរដើម្បីធ្វើការសរុបនូវខ្លឹមសារមួយផ្នែកដាក់នៅក្នុងទំព័រចុងក្រោយតែប៉ុណ្ណោះ ដោយផ្អែកធ្វើការពិចារណាអំពីភាពងាយស្រួលនៃការអានខ្លឹមសារទាំងស្រុងនៃអត្ថបទ។ ប្រសិនបើនៅក្នុង លិខិតសាលក្រម មានការដកស្រង់ខ្លឹមសារទៅដាក់នៅក្នុងឧបសម្ព័ន្ធនោះមានន័យថា គេគ្រាន់តែបានយកខ្លឹមសារមួយផ្នែកដែលមានភាពចាំបាច់ត្រូវសរសេរនៅក្នុងលិខិតសាលក្រមមកសរសេរសរុបដាក់នៅក្នុងទំព័រចុងក្រោយតែប៉ុណ្ណោះ ហើយ**ខ្លឹមសារនៃលិខិតសាលក្រមក៏រួមបញ្ចូលទាំងឧបសម្ព័ន្ធ**ផងដែរ។

រីឯ ឯកសារភ្ជាប់ ជាឯកសារដែលគេបានយកមកភ្ជាប់ជាមួយឯកសារដើម ហើយឯកសារភ្ជាប់នេះមិនមែនជាផ្នែកមួយនៃឯកសារដើមឡើយ។

[6] មាត្រា ១២៣ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ចំណុចនេះនឹងត្រូវសរសេរអំពីអង្គហេតុដែលភាគីបានសារភាពនៅចំពោះមុខតុលាការ និង អង្គហេតុដែលតុលាការយល់ឃើញថា អត្ថិភាពនៃអង្គហេតុនោះមានភាពជាក់ស្ដែង។

ខ.២.២. "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ត្រូវបានធ្វើឡើងជាលិខិតយថាភូត[7]។

ខ.២.៣. ដើមចោទបានព្រមព្រៀងបង់ប្រាក់កក់ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិកចំពោះការចុះ "កិច្ចសន្យានៃរឿងក្តីនេះ" ជាមួយចុងចម្លើយ ហើយបានប្រគល់ប្រាក់នេះឲ្យទៅចុងចម្លើយ។

ខ.២.៤. នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៨ ចុងចម្លើយបានធ្វើសំណើផ្តល់ [8]ប្រាក់ជាក់ស្តែងចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិកនៅផ្ទះរបស់ដើមចោទ (ផ្ទះលេខ ០០ ផ្លូវលេខ ០០ សង្កាត់ទំនប់ទឹក ខណ្ឌចំការមនរាជធានីភ្នំពេញ) ហើយបានបង្ហាញឆន្ទៈថា នឹងរំលាយ "កិច្ចសន្យានៃរឿងក្តីនេះ" [9]។

សំអាងហេតុ

ក. ការវិនិច្ឆ័យអំពីការទាមទារ

ផ្អែកតាមអង្គហេតុដែលគូភាគីគ្មានវិវាទ តុលាការទទួលស្គាល់ថា "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ត្រូវបានចុះរវាងដើមចោទ និង ចុងចម្លើយមានសុពលភាព ប៉ុន្តែចុងចម្លើយដែលជាភាគីអ្នកលក់បានរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ដោយធ្វើសំណើផ្តល់ប្រាក់ជាក់ស្តែងចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិកដែលជាចំនួនទឹកប្រាក់ពីរដងនៃចំនួនប្រាក់កក់ដែលត្រូវបានប្រគល់នៅពេលចុះ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" (យោងមាត្រា ៥១៨ នៃក្រមរដ្ឋប្បវេណី)។

ដូច្នេះហើយ ការទាមទាររបស់ដើមចោទដែលទាមទារនូវការប្រគល់ "ដី L" និងការធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល ដោយផ្អែកតាម "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" គឺពុំមានមូលហេតុទេ (កថាខណ្ឌទី ១ មាត្រា ៤១៤ និង កថាខណ្ឌទី ១ មាត្រា ៤១១ នៃក្រមរដ្ឋប្បវេណី)។

---

[7] ក្រមរដ្ឋប្បវេណី មាត្រា ៣៣៦ កថាខណ្ឌទី ២។ អង្គហេតុដែលមានភាពចាំបាច់ដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់នូវ "កិច្ចសន្យានៃរឿងក្តីនេះ" ដែលបានបង្កើតឡើងដោយមានសុពលភាព។ (ការពន្យល់លម្អិត សូមយោងតាម Footnote នៃពាក្យបណ្តឹង។)

[8] ការពន្យល់លម្អិតអំពីពាក្យថា "ការធ្វើសំណើផ្តល់ជាក់ស្តែង" សូមយោងតាម Footnote នៃឯកសារចម្លើយ។

[9] មាត្រា ៥១៨ មាត្រា ៤១៤ កថាខណ្ឌទី ១ មាត្រា ៤០៩ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី ។ (ការពន្យល់លម្អិត សូមយោងតាម Footnote នៃឯកសារចម្លើយ។)

ខ. ស្ដីពីបន្ទុកនៃប្រាក់ប្រដាប់ក្ដី

ដោយសារតែការទាមទារទាំងអស់របស់ដើមចោទពុំមានមូលហេតុ ដូច្នេះ ប្រាក់ប្រដាប់ក្ដី គឺជាបន្ទុករបស់ដើមចោទ (មាត្រា ៦៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

សេចក្ដីសម្រេចបញ្ចប់

១. ច្រានចោលការទាមទារទាំងអស់របស់ដើមចោទ។

២. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ ។

សាលក្រមនេះត្រូវបានប្រកាសនៅសវនការជាសាធារណៈនៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៩ ។ ក្នុងករណីដែលប្ដឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងនៅក្នុងរយៈពេល ០១ (មួយ) ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

ថ្ងៃអង្គារ ១១ រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃ ទី៣០ ខែ មេសា ឆ្នាំ២០១៩

ចៅក្រម

ឧបសម្ព័ន្ធ

បញ្ជី[10]

“គោលបំណងនៃពាក្យសុំចុះបញ្ជី”	ផ្ទេរកម្មសិទ្ធិទាំងមូល
“មូលហេតុននៃពាក្យសុំចុះបញ្ជី និង កាលបរិច្ឆេទ”	ការលក់ទិញចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៨
“បុគ្គលមានសិទ្ធិចុះបញ្ជី”	ដើមចោទ (X) ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃ......ខែ..........ឆ្នាំ......... ទីកន្លែងកំណើត ៖ .... ឈ្មោះរបស់ឪពុកម្តាយ៖ ....(ឪពុក) ....(ម្តាយ)
“បុគ្គលមានកាតព្វកិច្ចចុះបញ្ជី”	ចុងចម្លើយ (Y) ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃ......ខែ..........ឆ្នាំ......... ទីកន្លែងកំណើត ៖ .... ឈ្មោះរបស់ឪពុកម្តាយ៖ ....(ឪពុក) ....(ម្តាយ)
“អត្តសញ្ញាណនៃអចលនវត្ថុ”	ទីតាំងដី ៖ ផ្លូវលេខ ១០២ ភូមិ ៣ សង្កាត់ ជ្រោយចង្វារ ខណ្ឌ ជ្រោយចង្វារ រាជធានីភ្នំពេញ លេខក្បាលដី៖ ១៣០៦

[10] នៅក្នុងសាលក្រម សាលដីកាដែលជំនួសឲ្យការបង្ហាញឆន្ទៈរបស់បុគ្គលមានកាតព្វកិច្ចចុះបញ្ជី ចាំបាច់ត្រូវតែមានការសរសេរទាំងអស់នូវចំណុចដែលចាំបាច់នៅពេលធ្វើពាក្យសុំចុះបញ្ជី (ឧទាហរណ៍ ៖ ចំពោះពាក្យសុំចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ គឺត្រូវសរសេរអំពីចំណុចដែលបានកំណត់នៅក្នុងប្រការ ២៦ និង ប្រការ ២៨ នៃប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី)។ ហើយត្រូវធ្វើការបញ្ជាក់ថា គ្មានភាពខ្វះចន្លោះឡើយ។